ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងខេត្តកណ្ដាល

# តាងនាមប្រជារាស្ត្រខ្មែរ
# សាលាដំបូងខេត្តកណ្ដាល

**សំណុំរឿងព្រហ្មទណ្ឌ**
លេខ ៩១០ អក
ចុះថ្ងៃទី២៩ ខែឧសភា ឆ្នាំ២០២៣
**សាលក្រមព្រហ្មទណ្ឌ**
លេខ ០៦០/ង
ចុះថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០២៤

បានបើកសវនាការជាសាធារណៈនៅថ្ងៃទី០៦ ខែមីនា ឆ្នាំ២០២៤ វេលាម៉ោង ២:០០ នាទីរសៀល ដោយមានសមាសភាព ៖

## ក្រុមប្រឹក្សាជំនុំជម្រះ

លោក [redacted] ចៅក្រមសាលាដំបូងខេត្តកណ្ដាល ជាប្រធានក្រុមប្រឹក្សា

លោក [redacted] ចៅក្រមសាលាដំបូងខេត្តកណ្ដាល ជាចៅក្រមប្រឹក្សា

លោក [redacted] ចៅក្រមសាលាដំបូងខេត្តកណ្ដាលជាចៅក្រមប្រឹក្សា

## តំណាងអយ្យការ

លោកស្រី [redacted] ព្រះរាជអាជ្ញារង នៃសាលាដំបូងខេត្តកណ្ដាល

## ក្រឡាបញ្ជីសវនាការ

លោកស្រី [redacted] ក្រឡាបញ្ជីសាលាដំបូងខេត្តកណ្ដាល

ដើម្បីជំនុំជម្រះលើសំណុំរឿងព្រហ្មទណ្ឌលេខ ៩១០ អក ចុះថ្ងៃទី២៩ ខែឧសភា ឆ្នាំ២០២៣ ដែលមាន៖

ជនជាប់ចោទឈ្មោះ [redacted] សុផាន់ណារ៉ា ភេទប្រុស អាយុ៤២ឆ្នាំ ជាតិខ្មែរ មុខរបរកម្មករសំណង់ ទីកន្លែងកំណើតខណ្ឌ[redacted]រាជធានីភ្នំពេញ ទីលំនៅបច្ចុប្បន្នភូមិរកាកោង ឃុំរកាកោងទី១ ស្រុកមុខកំពូល ខេត្តកណ្ដាល ឪពុកឈ្មោះ [redacted] ផាន់ណា (ស) ម្ដាយឈ្មោះ [redacted] ចិនធី (រ) មានប្រពន្ធឈ្មោះ [redacted] ស្រីនាង (រ) មានកូនចំនួន០២នាក់ កម្រិតវប្បធម៌ថ្នាក់ទី៥ ជាទីតិជន ទោសពីមុន គ្មាន (ក្នុងឃុំ) ។

ដីកាបង្គាប់ឱ្យឃុំខ្លួនលេខ ២៤១៩ ចុះថ្ងៃទី២៩ ខែឧសភា ឆ្នាំ២០២៣ ។

ជាប់ចោទពីបទ **អំពើលួច (មានស្ថានទម្ងន់ទោសដោយសារការកាប់គាស់ទម្លុះទម្លាយ)** ប្រព្រឹត្តនៅភូមិរកាកោង ឃុំរកាកោងទី១ ស្រុកមុខកំពូល ខេត្តកណ្ដាល កាលពីថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០២២ តាមបញ្ញត្តិមាត្រា ៣៥៣ និងមាត្រា ៣៥៧ នៃក្រមព្រហ្មទណ្ឌ។

ដោយមានលោក [redacted] ជាមេធាវីការពារសិទ្ធិ ។



Scanned with CamScanner

# អង្គហេតុដែលបញ្ជូនមកជំនុំជម្រះ

កាលពីថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០២៣ វេលាម៉ោង២១ និង ៣០នាទី ស្ថិតនៅចំណុចផ្សារកាកោង ភូមិរកាកោង ឃុំរកាកោងទី១ ស្រុកមុខកំពូល ខេត្តកណ្តាល ជនជាប់ចោទឈ្មោះ[redacted]សុផាន់ណារ៉ា បានចេញពីបន្ទប់ជួលរបស់ខ្លួន ដោយបានយករណារអាដែកចំនួន០១ កន្ត្រៃកាត់ខោអាវចំនួន០១ ឈើនីវបន្ទះប្រវែង៨០សង់ទីម៉ែត្រ ខ្សែជ័រលីឡុង ដើរទៅតូបលក់មាសរបស់ជនរងគ្រោះឈ្មោះ [redacted] កូឡា បន្ទាប់មកក៏បានធ្វើសកម្មភាពឡើងទៅលើដំបូលតូបយកកន្ត្រៃកាត់ស័ង្កសី ហើយក៏បានត្រឡប់មកផ្ទះវិញ។ លុះដល់ថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០២៣ វេលាម៉ោង២២ និង២០នាទី ស្រាប់តែជនជាប់ចោទខាងលើបានធ្វើសកម្មភាពឡើងទៅលើដំបូលតូបលក់មាសម្តងទៀត រួចបើកដំបូលដែលបានកាត់រួច ហើយលោតចូលតូបលក់មាស យកកន្ត្រៃគាស់កិទូដាក់គ្រឿងអលង្ការរបស់ជនរងគ្រោះ លួចយកចិញ្ចៀនផ្កាកទីនចំនួន ៦៣វង់ និងប្រាក់រៀលចំនួន ១.១៦០.០០០ (មួយលានដប់ប្រាំមួយម៉ឺន) រៀល ។ លុះដល់ថ្ងៃទី២៧ ខែឧសភា ឆ្នាំ២០២៣ ទើបកម្លាំងសមត្ថកិច្ចបានធ្វើការឃាត់ខ្លួនជនជាប់ចោទខាងលើ មកកាន់អធិការដ្ឋាននគរបាលស្រុកមុខកំពូល ដើម្បីកសាងសំណុំរឿងនិងចាត់ការតាមនីតិវិធីច្បាប់តែម្តង។

-បានឃើញ របាយការណ៍លេខ ៣០០ របក ចុះថ្ងៃទី២៨ ខែឧសភា ឆ្នាំ២០២៣ របស់អធិការដ្ឋាននគរបាលស្រុកមុខកំពូល ខេត្តកណ្តាល ។

-បានឃើញ ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលេខ ៧២១ ដកសស ចុះថ្ងៃទី២៩ ខែឧសភា ឆ្នាំ ២០២៣ របស់អយ្យការអមសាលាដំបូងខេត្តកណ្តាល ។

-បានឃើញ ដីកាសន្និដ្ឋានស្ថាពរលេខ ១៤៦៣ ដកសព ចុះថ្ងៃទី១៣ ខែវិច្ឆិកា ឆ្នាំ២០២៣ របស់អយ្យការអមសាលាដំបូងខេត្តកណ្តាល ។

-បានឃើញ ដីកាដំណោះស្រាយលេខ ១៥៤៥ ដកដស ចុះថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០២៣ របស់សាលាដំបូងខេត្តកណ្តាល ។

## នាពេលសវនាការ

-ជនជាប់ចោទឈ្មោះ [redacted]សុផាន់ណារ៉ា បានឆ្លើយថា៖ ខ្លួនទទួលយកការចោទប្រកាន់ ដោយកាលពីថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០២៣ ខ្លួនបានយករណារអាដែកចំនួន ០១ កន្ត្រៃកាត់ខោអាវចំនួន ០១ និងបន្ទះឈើនីវប្រវែងប្រហែល៨ តឹក ដើរចេញពីផ្ទះ គោលបំណងទៅកាត់ស័ង្កសីនៅតូបលក់មាសរបស់ឈ្មោះ [redacted] កូឡា ដែលត្រូវជាកូនប្រសាររបស់ឈ្មោះ [redacted] ផន នៅក្នុងផ្សាររកាកោង។ ពេលខ្លួនដើរទៅដល់តូបលក់



Scanned with CamScanner

មាសនោះ នៅវេលាម៉ោងប្រហែល ១០យប់ ដោយឃើញស្ងាត់មិនមានមនុស្ស ខ្លួនក៏បានធ្វើសកម្មភាពឡើងទៅលើដំបូលតូបលក់មាសនោះ ហើយក៏យកកន្ត្រៃកាត់ដំបូលស័ង្កសីមួយប្រឡោះ ទំហំប្រហែល ៤ តឹកបួនជ្រុង រួចខ្លួនក៏ចុះមកវិញ និងដើរទៅកាត់ខ្សែកាមេរ៉ាសុវត្ថិភាពរួចផ្ដាច់ចោល។ ក្រោយពីធ្វើសកម្មភាពកាត់ស័ង្កសី និងកាត់កាមេរ៉ាសុវត្ថិភាព តែមិនបានលួចសម្ភារៈនៅក្នុងនោះទេ ហើយខ្លួនក៏បានដើរមកផ្ទះវិញ ។ លុះដល់ថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០២៣ វេលាម៉ោង ១០ និង០០ នាទីយប់ ខ្លួនបានចេញពីផ្ទះតែម្នាក់ឯង គោលបំណងទៅលួចសម្ភារៈនៅតូបលក់មាសរបស់ឈ្មោះ [redacted] កូឡា ដែលខ្លួនបានកាត់ទុកកាលពីថ្ងៃមុននោះ។ ពេលខ្លួនទៅដល់ មិនមានមនុស្សនៅទីនោះទេ ខ្លួនក៏បានឡើងទៅលើដំបូលតូប ហើយចុះតាមប្រឡោះស័ង្កសីដែលខ្លួនបានកាត់ទុកនោះ រួចធ្វើសកម្មភាពយកកន្ត្រៃគាស់ទូគ្រឿងអលង្ការ និងលួចយកចិញ្ចៀនផ្លាកទីនចំនួន ០១ថង់ (មិនដឹងប៉ុន្មានវង់) និងប្រាក់ចំនួន ១.០៥០.០០០ (មួយលានប្រាំម៉ឺន)រៀល បន្ទាប់មកក៏ត្រឡប់ទៅផ្ទះ។ លុះដល់ថ្ងៃទី២៧ ខែឧសភា ឆ្នាំ២០២៣ ស្រាប់តែមានសមត្ថកិច្ចបានហៅខ្លួនទៅបំភ្លឺនៅប៉ុស្តិ៍នគរបាលរដ្ឋបាលឃុំរកាកោងទី១ តែម្ដង ។ ចំពោះគ្រឿងអលង្ការ និងប្រាក់ដែលខ្លួនបានលួចមកនោះ ខ្លួនបានប្រគល់ឱ្យម្ចាស់ដើមវិញអស់ហើយ។ សំណូមពរ សុំឱ្យតុលាការបន្ធូរបន្ថយទោស ។

-អំណានចម្លើយជនរងគ្រោះឈ្មោះ [redacted] កូឡា បានឆ្លើយថា៖ កាលពីថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០២៣ វេលាម៉ោង ៥ និង៣០ នាទីព្រឹក ខ្លួនបានចេញពីផ្ទះទៅបើកតូបលក់គ្រឿងអលង្ការរបស់ខ្លួនដូចធម្មតា ពេលបើកតូបរួចភ្លាម ក៏ឃើញមានស្នាមចោរគាស់តូបកាត់ពីដានខាងលើ និងគាស់ថតតុយកគ្រឿងអលង្ការ និងប្រាក់មួយចំនួន។ ភ្លាមនោះ ខ្លួនបានឃើញសមត្ថកិច្ចកំពុងអង្គុយញ៉ាំគុយទាវនៅជិតតូបរបស់ខ្លួន ខ្លួនក៏បានប្ដឹងសមត្ថកិច្ចតែម្ដង បន្ទាប់មកសមត្ថកិច្ចបានសុំមើលកាមេរ៉ាសុវត្ថិភាព តែកាមេរ៉ាសុវត្ថិភាពរបស់ខ្លួនមើលមិនឃើញទេ ព្រោះឈ្មោះ [redacted] សុផាន់ណា បានលួចកាត់ខ្សែកាមេរ៉ាសុវត្ថិភាព ហើយក៏សុំមើលកាមេរ៉ាតូបអ្នកលក់ជិតខ្លួន ក៏ឃើញថា ឈ្មោះ [redacted] សុផាន់ណា បានគាស់តូប លួចយកប្រាក់ និងគ្រឿងអលង្ការរបស់ខ្លួន។ ខ្លួនបានបាត់ចិញ្ចៀនចំនួន ៩៥វង់ និងប្រាក់ចំនួន ១.០៥០.០០០(មួយលានប្រាំម៉ឺន)រៀល ហើយបន្ទាប់ពីសមត្ថកិច្ចឃាត់ខ្លួន ជនជាប់ចោទក៏បានយកគ្រឿងអលង្ការ និងប្រាក់ទាំងនោះមកខ្លួនវិញ។ បច្ចុប្បន្នខ្លួនបានទទួលប្រាក់ និងគ្រឿងអលង្ការមកវិញហើយ។ ខ្លួនបានស្នើសុំធ្វើការដកពាក្យបណ្ដឹង ដោយរូបខ្លួនមិនទាមទារសំណងការខូចខាតពីជនប្រព្រឹត្តនោះទេ ព្រោះខ្លួនជាប់រវល់រកស៊ីលក់ដូរ ដោយផ្ទះរបស់ខ្លួននៅឆ្ងាយពីតុលាការ ពិបាកធ្វើដំណើរចុះឡើង មួយវិញទៀតគ្រួសាររបស់ជនជាប់ចោទ គឺមានជីវភាពខ្វះខាតដែរ។ ✓



Scanned with CamScanner

-អំណានចម្លើយជនរងគ្រោះឈ្មោះ [redacted] ស្រីឡូត បានឆ្លើយថា៖ កាលពីថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០២៣ វេលាម៉ោង ២២ និង ២០នាទី ឈ្មោះ [redacted] សុផាន់ណា បានធ្វើសកម្មភាពនៅកន្លែងតូបលក់មាសរបស់ខ្លួន ដោយមែមានកាន់ផង់បានធ្វើសកម្មភាពកាត់ខ្សែកាំមេរ៉ាសុវត្ថិភាពចោល។ ដល់ថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០២៣ ស្រាប់តែជនជាប់ចោទធ្វើសកម្មភាព កាត់ជម្រើងដែកដំបូលតូបលក់មានរបស់ខ្លួន គាស់តុលួចយកគ្រឿងអលង្ការ មានចិញ្ចៀនផ្កាកទីនទឹកបី និងទឹកប្រាំពីរ ចំនួន៩៥វង្ស សរុបទម្ងន់ ៨តំឡឹង និងប្រាក់រៀលថ្មី ក្រដាស ៥០០រៀល ក្រដាស ២០០រៀល ក្រដាស ១០០រៀល សរុបចំនួន ២.០៤០.០០០រៀល (ពីរលានបួនម៉ឺនរៀល) ក្រោយមកខ្លួននិងប្តីឈ្មោះ [redacted] កូឡា បានទៅរាយការណ៍ជូនសមត្ថកិច្ចប៉ុស្តិ៍នគរបាលរកាកោងទី១ឱ្យជួយស្រាវជ្រាវរកជនជាប់ចោទតែម្តង។

-តំណាងអយ្យការបានធ្វើសេចក្តីសន្និដ្ឋានប្តឹងសុំថា៖ តាមចម្លើយរបស់ជនរងគ្រោះថា ជនជាប់ចោទបានផ្តាច់ខ្សែកាំមេរ៉ារបស់ខ្លួន លុះខ្លួនទៅសុំកាំម៉េរ៉ារបស់អ្នកជិតខាង ទើបដឹងរឿង ។ ជនជាប់ចោទពិតជាបានប្រព្រឹត្តដូចការចោទប្រកាន់មែន ហេតុនេះស្នើសុំតម្កល់ការចោទប្រកាន់ទុកជាបានការដដែល ។

-លោក [redacted] មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ បានសន្និដ្ឋានថា៖ កូនក្តីខ្លួនបានឆ្លើយសារភាព តែការលួចនេះគឺដោយសារការឆោតល្ងង់ និងជីវភាពក្រីក្រ សំណូមពរសុំឱ្យតុលាការផ្តល់ស្ពានសម្រាលទោសដល់កូនក្តីខ្លួន ។

ក្រោយពីបានស្តាប់ចម្លើយរបស់ជនជាប់ចោទ

ក្រោយពីស្តាប់អំណានចម្លើយរបស់ជនរងគ្រោះ

ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានប្តឹងសុំរបស់តំណាងអយ្យការ

ក្រោយពីបានស្តាប់ការសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ

ក្រោយពីបានពិនិត្យភស្តុតាង និងពិចារណាត្រឹមត្រូវតាមច្បាប់ហើយ

## សំអាងហេតុ

១-កាលពីថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០២៣ វេលាម៉ោង២១ និង ៣០នាទី ស្ថិតនៅចំណុចផ្សាររកាកោង ភូមិរកាកោង ឃុំរកាកោងទី១ ស្រុកមុខកំពូល ខេត្តកណ្តាល ជនជាប់ចោទឈ្មោះ [redacted] សុផាន់ណារ៉ាបានចេញពីបន្ទប់ជួលរបស់ខ្លួន ដោយបានយករណារដែកចំនួន០១ កន្ត្រៃកាត់ខោអាវចំនួន០១ ឈើនីវបន្ទះប្រវែង ៨០សង់ទីម៉ែត្រ ខ្សែជ័រលឿង ដើរទៅតូបលក់មាសរបស់ជនរងគ្រោះឈ្មោះ [redacted] កូឡា បន្ទាប់មកក៏បានធ្វើសកម្មភាពឡើងទៅលើដំបូលតូបយកកន្ត្រៃកាត់សង្កសី ហើយក៏បានត្រឡប់មកផ្ទះវិញ។ លុះដល់ថ្ងៃ



Scanned with CamScanner

ទី២៥ ខែឧសភា ឆ្នាំ២០២៣ វេលាម៉ោង២២ និង២០នាទី ស្រាប់តែជនជាប់ចោទខាងលើបានធ្វើសកម្មភាព ឡើងទៅលើដំបូលតូបលក់មាសម្តងទៀត រួចបើកដំបូលដែលបានកាត់រួច ហើយលោតចូលតូបលក់មាស យកកន្ត្រៃគាស់កិទូដាក់គ្រឿងអលង្ការរបស់ជនរងគ្រោះ លួចយកចិញ្ចៀនផ្កាកទីនចំនួន ៦៣វង់ និងប្រាក់ រៀលចំនួន ១.១៦០.០០០ (មួយលានដប់ប្រាំមួយម៉ឺន) រៀល ។ លុះដល់ថ្ងៃទី២៧ ខែឧសភា ឆ្នាំ២០២៣ ទើបកម្លាំងសមត្ថកិច្ចបានធ្វើការឃាត់ខ្លួនជនជាប់ចោទខាងលើមកកាន់អធិការដ្ឋាននគរបាលស្រុកមុខកំពូល ដើម្បីកសាងសំណុំរឿងនិងចាត់ការតាមនីតិវិធីច្បាប់តែម្តង។

២-នាពេលសវនាការដេញដោល ជនជាប់ចោទឈ្មោះ [redacted] សុផាន់ណារ៉ា បានឆ្លើយសារភាពថា ខ្លួនពិតជាបានប្រព្រឹត្តដូចការចោទប្រកាន់មែន ។ ឃើញថា ជនជាប់ចោទបានឆ្លើយសារភាព ដែលចម្លើយសារភាពនេះគឺស៊ីសង្វាក់នឹងចម្លើយជនរងគ្រោះ គប្បីតុលាការពិចារណា ។

៣-តាមរបាយការណ៍លេខ ៣០០ របក ចុះថ្ងៃទី២៨ ខែឧសភា ឆ្នាំ២០២៣ របស់អធិការដ្ឋាននគរបាលស្រុកមុខកំពូល បានសន្និដ្ឋានថា ឈ្មោះ [redacted] សុផាន់ណារ៉ា ពិតជាបានប្រព្រឹត្ត **អំពើលួច** គ្រឿងអលង្ការ និងប្រាក់របស់ជនរងគ្រោះឈ្មោះ [redacted] កូឡា ប្រាកដមែន។

៤-តាមចម្លើយសារភាពរបស់ជនជាប់ចោទ ចម្លើយរបស់ជនរងគ្រោះ របាយការណ៍របស់សមត្ថកិច្ច និងភស្តុតាងក្នុងសំណុំរឿង ឃើញថាមានភាពស៊ីសង្វាក់គ្នាទៅនឹងអង្គហេតុ ដែលអាចបញ្ជាក់ថា កាលពីកាលពីថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០២៣ វេលាម៉ោង២១ និង ៣០នាទី ស្ថិតនៅចំណុចផ្សារកាកោង ភូមិកាកោង ឃុំកាកោងទី១ ស្រុកមុខកំពូល ខេត្តកណ្តាល ជនជាប់ចោទឈ្មោះ [redacted] សុផាន់ណារ៉ា បានឡើងទៅលើដំបូងតូបលក់មាសរបស់ជនរងគ្រោះឈ្មោះ [redacted] កូឡា និងប្រពន្ធឈ្មោះ [redacted] ស្រីឡូត ហើយយកកន្ត្រៃកាត់ដំបូលស័ង្កសី ហើយក៏បានត្រឡប់មកផ្ទះវិញ ។ លុះដល់ថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០២៣ វេលាម៉ោង២២ និង២០នាទី ស្រាប់តែជនជាប់ចោទបានឡើងទៅលើដំបូលតូបលក់មាសម្តងទៀត រួចបើកដំបូលដែលបានកាត់រួច ហើយលោតចូលតូបលក់មាស លួចយកចិញ្ចៀនផ្កាកទីនចំនួន ៦៣វង់ និងប្រាក់រៀលចំនួន ១.១៦០.០០០ (មួយលានដប់ប្រាំមួយម៉ឺន) រៀល ប្រាកដមែន ។

៥-មានភស្តុតាង និងពិរុទ្ធភាពគ្រប់គ្រាន់លើជនជាប់ចោទឈ្មោះ [redacted] សុផាន់ណារ៉ា ពីបទ **អំពើលួច (មានស្ថានទម្ងន់ទោសដោយសារការកាប់គាស់ទម្លុះទម្លាយ)** ប្រព្រឹត្តនៅភូមិកាកោង ឃុំកាកោងទី១ ស្រុកមុខកំពូល ខេត្តកណ្តាល កាលពីថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០២២ តាមបញ្ញត្តិមាត្រា ៣៥៣ និងមាត្រា ៣៥៧ នៃក្រមព្រហ្មទណ្ឌ។ ៤



Scanned with CamScanner

៦-តំណាងអយ្យការបានធ្វើសេចក្តីសន្និដ្ឋានប្តឹងសុំថា ជនជាប់ចោទពិតជាបានប្រព្រឹត្តដូចការចោទប្រកាន់មែន ហេតុនេះស្នើសុំតម្កល់ការចោទប្រកាន់ទុកជាបានការដដែល គប្បីតុលាការពិចារណា ។

៧-លោកមេធាវីការពារសិទ្ធិឲ្យជនជាប់ចោទបានសន្និដ្ឋានថា កូនក្តីខ្លួនបានឆ្លើយសារភាព តែការលួចនេះគឺដោយសារការឆោតល្ងង់ និងជីវភាពក្រីក្រ សំណូមពរសុំឲ្យតុលាការផ្តល់ស្ថានសម្រាលទោសដល់កូនក្តីខ្លួន ។ ដោយសារតែបទល្មើសនេះកំពុងមានការកើនឡើងខ្លាំងនាពេលបច្ចុប្បន្ន បង្កជាភាពប្រច្របល់ប៉ះពាល់ដល់សណ្តាប់ធ្នាប់សាធារណៈយ៉ាងធ្ងន់ធ្ងរ ដែលគប្បីត្រូវមានការអនុវត្តច្បាប់ឲ្យបានតឹងរ៉ឹង ហេតុនេះគប្បីតុលាការមិនលើកយកការស្នើសុំនេះមកធ្វើការពិចារណាឡើយ ។

## ហេតុដូច្នេះសម្រេច

១-ផ្តន្ទាទោសឈ្មោះ [redacted] សុផាន់ណារ៉ា ភេទប្រុស អាយុ៤២ឆ្នាំ (ក្នុងឃុំ) ដាក់ពន្ធនាគារកំណត់ **០៤(បួន)ឆ្នាំ ពីបទ អំពើលួច (មានស្ថានទម្ងន់ទោសដោយសារការកាប់គាស់ទម្លុះទម្លាយ)** ប្រព្រឹត្តនៅភូមិកាកោង ឃុំកាកោងទី១ ស្រុកមុខកំពូល ខេត្តកណ្តាល កាលពីថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០២២ តាមបញ្ញត្តិមាត្រា ៣៥៣ និងមាត្រា ៣៥៧ នៃក្រមព្រហ្មទណ្ឌ។

២-សាលក្រមនេះជំនុំជម្រះជាសាធារណៈ ថ្ងៃទី០៦ ខែឧសភា ឆ្នាំ២០២៤ និងប្រកាសជាសាធារណៈ **ថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០២៤** ចំពោះមុខជនជាប់ចោទឈ្មោះ **យូ សុផាន់ណារ៉ា** ។

-បើកសិទ្ធិប្តឹងឧទ្ធរណ៍ក្នុងកំណត់ច្បាប់ ។

| **ក្រឡាបញ្ជីសវនាការ** | **ចៅក្រមប្រឹក្សា** | **ប្រធានក្រុមប្រឹក្សាជំនុំជម្រះ** |
|---|---|---|
| ហត្ថលេខា និងត្រា | ហត្ថលេខា និងត្រា | ហត្ថលេខា និងត្រា |

[redacted]

"បានចម្លងត្រឹមត្រូវតាមច្បាប់ដើម"

ថ្ងៃព្រហស្បតិ៍ ១រោច ខែពិសាខ ឆ្នាំរោង ឆស័ក ព.ស ២៥៦៨

កណ្តាល,ថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០២៤

**ក្រឡាបញ្ជី**

[redacted]

បានឃើញ

**ប្រធានក្រុមប្រឹក្សាជំនុំជម្រះ**

[redacted]



Scanned with CamScanner